ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

# ស្តង់ដាទីក្រុងស្អាត

# សង្ខេបមាតិកា

**សេចក្តីផ្តើម** .......... **១**

I. **សូចនាករនៃការវាយតម្លៃទីក្រុងស្អាត** .......... **៣**

១. សូចនាករគោលនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន(មាន៨សូចនាកររលំអិត) .......... ៣

២. សូចនាករគោលនៃភាពស្អាត(មាន៦សូចនាកររលំអិត) .......... ៤

៣. សូចនាករគោលនៃការគ្រប់គ្រងសំណល់ (មាន៥សូចនាកររលំអិត) .......... ៦

៤. សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង(មាន៣សូចនាកររលំអិត) .......... ៧

៥. សូចនាករគោលនៃតំបន់បៃតង(មាន៣សូចនាកររលំអិត) .......... ៧

៦. សូចនាករគោលនៃសុវត្ថិភាពសុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង (មាន៣សូចនាកររលំអិត) .......... ៨

៧. សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ (មាន៤សូចនាកររលំអិត) .......... ៩

II. **យន្តការនៃការប្រឡងប្រណាំងទីក្រុងស្អាត** .......... **១១**

III. **ដំណើរការនៃការប្រឡងប្រណាំង** .......... **១២**

## សេចក្តីផ្តើម

ស្តង់ដារទីក្រុងស្អាតចែកចេញជា **៧**សូចនាករគោល រួមមាន**៣៣**សូចនាករលំអិតដែលត្រូវបានរាប់បញ្ចូល និងត្រូវបានដាក់ពិន្ទុតាមរយៈលក្ខណវិនិច្ឆ័យចំនួន**៧៧**។

ការរៀបរៀងត្រូវបានរៀបចំឡើងយោងតាមសារៈសំខាន់នៃសូចនាករគោលខុសគ្នា ៖បណ្តុំនៃសូចនាករលំអិតមួយក្រុមៗនឹងត្រូវបានដាក់ពិន្ទុទៅតាមលក្ខណវិនិច្ឆ័យខុសៗគ្នា ៖

- មាន ៨ សូចនាករលំអិតនៃការគ្រប់គ្រង និងរៀបចំបរិស្ថាន ៖ ឱ្យពិន្ទុលើ ១៣ លក្ខណវិនិច្ឆ័យ
- មាន ៦ សូចនាករលំអិតនៃភាពស្អាត ៖ ឱ្យពិន្ទុលើ ១៧ លក្ខណវិនិច្ឆ័យ
- មាន ៥ សូចនាករលំអិតនៃការគ្រប់គ្រងសំណល់ ៖ ឱ្យពិន្ទុលើ ៨ លក្ខណវិនិច្ឆ័យ
- មាន ៣ សូចនាករលំអិតនៃបញ្ជ្រាបការយល់ដឹង ៖ ឱ្យពិន្ទុលើ ៧ លក្ខណវិនិច្ឆ័យ
- មាន ៣ សូចនាករលំអិតនៃតំបន់បៃតង ៖ ឱ្យពិន្ទុលើ ៤ លក្ខណវិនិច្ឆ័យ
- មាន ៣ សូចនាករលំអិតនៃសុវត្ថិភាពសុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង ៖ ឱ្យពិន្ទុលើ ១៤ លក្ខណវិនិច្ឆ័យ
- មាន ៥ សូចនាករលំអិតនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ ៖ ឱ្យពិន្ទុលើ ១៤ លក្ខណវិនិច្ឆ័យ

យោងទៅតាមកម្មវត្ថុទាំងឡាយដែលជាគំនិតផ្តួចផ្តើមឱ្យមានការប្រឡងប្រណាំងទីក្រុងស្អាត ការប្រឡងប្រណាំងត្រូវបានពឹងផ្អែកជាសំខាន់ទៅលើសូចនាករគោលធំៗចំនួន ០៤ ក្នុងចំណោមសូចនាករគោលធំៗទាំង៧គឺ ៖ ភាពស្អាត ការគ្រប់គ្រងសំណល់ ការបញ្ជ្រាបការយល់ដឹង និងសុវត្ថិភាពសុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង។

លក្ខណវិនិច្ឆ័យនៃសូចនាករគោលធំៗទាំង ៤ ផ្តល់ពិន្ទុលើសពី ៧០% នៃពិន្ទុសរុប (ក្នុងនោះសូចនាករគោលនៃភាពស្អាតស្រូបយកពិន្ទុស្មើនឹង៣០%នៃពិន្ទុសរុប)។

## I. តារាងសូចនាករនៃការវាយតម្លៃទីក្រុងស្អាត

### ១. សូចនាករគោលនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន (មាន៨សូចនាករលំអិត)

| សូចនាករគោលនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១-E1 សូចនាករលំអិតនៃការរៀបចំទីក្រុង | វត្តមាននៃប្លង់គោលប្រើប្រាស់ដីទីក្រុង | មាន-មិនមាន | ១ |
| | វត្តមាននៃផែនការប្រើប្រាស់ដីទីក្រុង | មាន-មិនមាន | ១ |
| | វត្តមាននៃគម្រោងអភិវឌ្ឍក្រុង | មាន-មិនមាន | ១ |
| ២-E2 សូចនាករលំអិតនៃលិខិតបទដ្ឋានគតិយុត្តស្តីអំពីបរិស្ថាន | វត្តមាននៃយន្តការដែលអាចដាក់ទណ្ឌកម្មដោយអាជ្ញាធរមូលដ្ឋាន (ការពិន័យជាប្រាក់ ឬការបិទអាជីវកម្ម) ចំពោះការមិនគោរព និងមិនចូលរួមថែរក្សាបរិស្ថាន (ដូចជាការបញ្ចេញសំណល់ឥតសណ្តាប់ធ្នាប់ ការមិនគោរពបទប្បញ្ញត្តិនគរូបនីយកម្ម។ល។) | មាន-មិនមាន | ១ |
| ៣-E3 សូចនាករលំអិតនៃគុណភាពទឹក | វត្តមាននៃការត្រួតពិនិត្យលើភាពស្អាតរបស់ទឹក (ទន្លេ ស្ទឹង សមុទ្រ) | មាន-មិនមាន | ១ |
| | វត្តមាននៃការត្រួតពិនិត្យលើភាពស្អាតរបស់ទឹកសម្រាប់បរិភោគ | មាន-មិនមាន | ១ |
| ៤-E4 សូចនាករលំអិតនៃគុណភាពខ្យល់ | មានវិធានការដែលទាក់ទងទៅនឹងគុណភាពខ្យល់ (ឧទាហរណ៍៖ គម្រោងនៃការកាត់បន្ថយការស្ទះចរាចរណ៍) | មាន-មិនមាន | ១ |
| ៥-E5 សូចនាករលំអិតនៃការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង | វត្តមាននៃវិធានការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង (សម្លេងមីក្រូ ខារ៉ាអូខេ។ល។) | មាន-មិនមាន | ១ |
| ៦-E6 សូចនាករលំអិតនៃដៃគូសហប្រតិបត្តិការ | វត្តមានដៃគូសហប្រតិបត្តិការ (ដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងសហប្រតិបត្តិការក្នុងតំបន់ដែលទាក់ទងនឹងការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាន ភាពស្អាត ឬការគ្រប់គ្រងសំណល់) | មាន-មិនមាន | ១ |
| ៧-E7 សូចនាករលំអិតនៃការធ្វើដំណើរដែលគិតគូរដល់បរិស្ថាន | វត្តមាននៃមធ្យោបាយធ្វើដំណើរដែលលើកទឹកចិត្តដល់ការគិតគូរពីបរិស្ថាន (ឧទាហរណ៍: ដូចជា រថយន្តក្រុង រថយន្តធ្វើដំណើរដោយថាមពលអគ្គិសនី។ល។) | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| ៨-E8 សូចនាករលំអិតនៃការប្រើប្រាស់ថាមពលដែលគិតគូរដល់បរិស្ថាន | វត្តមានសកម្មភាពនិងវិធានការលើកទឹកចិត្តដល់សម្បទាទេសចរណ៍ (សណ្ឋាគារ ភោជនីយដ្ឋាន។ល។) និងប្រជាពលរដ្ឋឱ្យប្រើប្រាស់ថាមពលដែលកកើតឡើងវិញ (Renewable Energy) | មាន-មិនមាន | ១ |
| | ភាគរយនៃការប្រើប្រាស់ថាមពលដែលកកើតឡើងវិញនៅតាមសម្បទាទេសចរណ៍(សណ្ឋាគារ ភោជនីយដ្ឋាន ។ល។) | យ៉ាងហោចណាស់មាន ៣០%នៃចំនួនសម្បទាទេស ចរណ៍សរុបក្នុងទីក្រុង | ១ |
| | វត្តមានសកម្មភាព និងវិធានការលើកទឹកចិត្តដល់សម្បទាទេសចរណ៍ (សណ្ឋាគារ ភោជនីយដ្ឋាន។ល។) និងប្រជាពលរដ្ឋក្នុងការសន្សំសំចៃការប្រើប្រាស់ថាម-ពល (Efficient Energy use) (ឧទាហរណ៍ ការប្រើប្រាស់អំពូលស៊ីថាមពលតិច ការប្រើប្រាស់សោរផ្តាច់អគ្គិសនីដោយស្វ័យប្រវត្តិតាមសណ្ឋាគារ។ល។) | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលំអិត ៖ ៨**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ១៣** | | **សរុប** | **១៣** |

២. <u>សូចនាករគោលនៃភាពស្អាត (មាន៦សូចនាករលំអិត)</u>

| **សូចនាករគោលនៃភាពស្អាត** | **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ៩-P1 សូចនាករលំអិតនៃភាពស្អាតនៅទីកន្លែងសាធារណៈ | ភាពស្អាតនៅតាមកន្លែងសំខាន់ៗ ដែលអាចជាកន្លែងទទួលសាធារណៈជន ដូចជា ការិយាល័យរដ្ឋបាលសាធារណៈ តំបន់បៃតង ទីស្នាក់ការព័ត៌មាន និងទីផ្សារសំខាន់ៗ | មាន-មិនមាន | ១ |
| | តើកន្លែងទាំងនោះ គឺជាកម្មវត្ថុនៃការថែរក្សា និងសម្អាតយ៉ាងទៀតទាត់ឬទេ? | យ៉ាងហោច១ដងក្នុង១ថ្ងៃ | ១ |
| | មានធុងសំរាមគ្រប់គ្រាន់នៅតាមទីកន្លែងសាធារណៈសំខាន់ៗ | មាន-មិនមាន | ១ |
| ១០-P2 សូចនាករលំអិតនៃភាពស្អាតនៅតាមបង្គន់ | មានបង្គន់សាធារណៈនៅតាមរមណីយដ្ឋានទេសចរណ៍ទាំងឡាយ | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| សាធារណៈ | ភាពស្អាតនៅតាមបង្គន់សាធារណៈទាំងនោះ | មាន-មិនមាន | ១ |
| | តើបង្គន់សាធារណៈទាំងនោះជាកម្មវត្ថុនៃការថែរក្សា និងសម្អាតយ៉ាងទៀងទាត់ដែរឬទេ? | យ៉ាងហោច៤ ដងក្នុង១ថ្ងៃ | ១ |
| **១១-P3** សូចនាករលំអិតនៃភាពស្អាតនៅតាមកន្លែង និងសម្បទាទេសចរណ៍ (សារមន្ទីរ ប្រាសាទ សួនកំសាន្ត ឆ្នេរ) | ភាពស្អាតនៅតាមទីរមណីយដ្ឋានសំខាន់ៗដែលបង្ហាញនូវភាពទទួលរាក់ទាក់ចំពោះភ្ញៀវទេសចណ៍ | មាន-មិនមាន | ១ |
| | តើរមណីយដ្ឋានទេសចរណ៍ទាំងនោះគឺជាកម្មវត្ថុនៃការថែរក្សា និងសម្អាតយ៉ាងទៀងទាត់ដែរឬទេ? | យ៉ាងហោច២ ដងក្នុង១ថ្ងៃ | ១ |
| | មានធុងសំរាមគ្រប់គ្រាន់នៅតាមទីរមណីយដ្ឋានទេស-ចរណ៍ | មាន-មិនមាន | ១ |
| **១២-P4** សូចនាករលំអិតនៃភាពស្អាតនៅតាមទីកន្លែង និងដងវិថីសំខាន់ៗ | ភាពស្អាតនៅតាមកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់នៅក្នុងទីក្រុង | មាន-មិនមាន | ១ |
| | តើកន្លែងទាំងនោះគឺជាកម្មវត្ថុនៃការសម្អាតជាប្រចាំដែរឬទេ? | យ៉ាងហោច២ ដងក្នុង១ថ្ងៃ | ១ |
| | មានធុងសំរាមគ្រប់គ្រាន់នៅតាមទីកន្លែងទាំងនោះដែរឬទេ? | មាន-មិនមាន | ១ |
| | តើមានវត្តមាននៃការគ្រប់គ្រងលើអាកប្បកិរិយា និងការកំណត់អំពីការស្លៀកពាក់របស់អ្នកបើកបររថយន្តឈ្នួល រ៉ឺម៉កកង់បី ម៉ូតូឌុប និងអ្នកដំណើរទាំងឡាយនៅលើដងវិថីសាធារណៈដែរឬទេ? | មាន-មិនមាន | ១ |
| **១៣-P5** សូចនាករលំអិតនៃភាពស៊ីគ្នានៃស្ថាបត្យកម្មរបស់តំបន់ដែលជាអគារសាធារណៈ និងផ្ទះរបស់ប្រជាពលរដ្ឋ | ភាពស៊ីសង្វាក់គ្នានៃរចនាបទរបស់អគារសាធារណៈ | មាន-មិនមាន | ១ |
| | ភាពស៊ីសង្វាក់គ្នានៃរចនាបទរបស់លំនៅដ្ឋានប្រជា-ពលរដ្ឋ។ | មាន-មិនមាន | ១ |
| **១៤-P6** សូចនាករលំអិតនៃការតុបតែងលំអនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍ | ភាពស៊ីសង្វាក់គ្នានៃការតុបតែងលំអនៅតាមទីរមណីយ-ដ្ឋាននានាស្របទៅនឹងលក្ខណៈពិសេសនៃតំបន់នីមួយៗ (Spécificité de la région) | មាន-មិនមាន | ១ |
| | ភាពស៊ីសង្វាក់គ្នានៃការតុបតែងលំអមធ្យោបាយដឹកជញ្ជូនទេសចរណ៍ | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលំអិត ៖ ៦**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ១៧** | | **សរុប** | **១៧** |

## ៣. សូចនាករគោលនៃការគ្រប់គ្រងសំណល់ (មាន៥សូចនាករលំអិត)

| សូចនាករគោលនៃការគ្រប់គ្រងសំណល់ | លក្ខណវិនិច្ឆ័យទៅលើការវាយតំលៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **១៥**-D1 សូចនាករលំអិតនៃការប្រមូលសំណល់រាវ | ភាគរយនៃប្រជាពលរដ្ឋដែលភ្ជាប់ខ្លួនទៅក្នុងបណ្តាញដែលមានវិធានការគ្រប់គ្រងលើទឹកដែលបានប្រើ-ប្រាស់រួច | យ៉ាងហោចណាស់មាន៣០%ដែលបានចូលរួម | ១ |
| | ភាពញឹកញាប់នៃការប្រមូលសំណល់រាវ (ឧទាហរណ៍ នៅតាមសណ្ឋាគារ។ល។) | យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ | ១ |
| **១៦**-D2 សូចនាករលំអិតនៃការប្រមូលសំណល់រឹង | ភាគរយនៃប្រជាពលរដ្ឋដែលស្ថិតនៅក្នុងការប្រមូលសំណល់រឹងជាទៀងទាត់ | អប្បបរមា៥០% | ១ |
| | ភាពញឹកញាប់នៃការប្រមូលសំណល់រឹង | យ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ | ១ |
| **១៧**-D3 សូចនាករលំអិតអំពីការស្តុក និងការធ្វើប្រព្រឹត្តកម្មលើសំណល់រាវ | លទ្ធភាពដែលអាចស្តុកសំណល់រាវ (មានបំពាក់ធុងស្តុកសំណល់រាវ) | មាន-មិនមាន | ១ |
| | ចំនួនភាគរយនៃសណ្ឋាគារ និងផ្ទះសំណាក់ដែលមានអាងស្តុកសម្រាប់ធ្វើប្រព្រឹត្តកម្មសំណល់រាវ | អប្បបរមា៥០% | ១ |
| **១៨**-D4 សូចនាករលំអិតនៃការស្តុក និងការធ្វើប្រព្រឹត្តកម្មលើសំណល់រឹង | លទ្ធភាពដែលអាចស្តុកសំណល់រឹង ក្រៅអំពីការស្តុកចោលដោយគ្មានការការពារឱ្យបានត្រឹមត្រូវ (ឧទាហរណ៍ ការស្តុកសំណល់រឹងដោយមានការជីកកប់ឱ្យបានត្រឹមត្រូវ) | មាន-មិនមាន | ១ |
| **១៩**-D5 សូចនាករលំអិតនៃការបែងចែកសំណល់រឹង | លទ្ធភាពដែលអាចឱ្យសហគ្រាសទាំងឡាយ និង/ឬ ប្រជាជនមូលដ្ឋានអាចធ្វើការបែងចែកសំណល់រវាងសំណល់ធម្មតានិងសំណល់ដែលមានជាតិពុល (ថ្មពិល អាគុយ ប្រេងដែលប្រើប្រាស់រួច។ល។) | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលំអិត ៖ ៥**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ៨** | | **សរុប** | ៨ |

## ៤. សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង (មាន៣សូចនាករលំអិត)

| សូចនករគោលនៃការបញ្ជ្រាបការយល់ដឹង | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **២០-I1** សូចនាករលំអិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់ប្រជាជនមូលដ្ឋាន | សកម្មភាពក្នុងការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់ប្រជាជនមូលដ្ឋាន(បើកការប្រជុំបង្កើតក្រុមគាំពារបរិស្ថាន ។ល។) | មាន-មិនមាន | ១ |
| | តើសកម្មភាពបញ្ជ្រាបការយល់ដឹងទាំងនេះត្រូវបានធ្វើឡើងញឹកញាប់ដែរឬទេ? | យ៉ាងហោចណាស់២ ដងក្នុងមួយឆ្នាំ | ១ |
| | វត្តមានមធ្យោបាយផ្តល់ព័ត៌មានអំពីបរិស្ថាន (បដាព័ត៌-មាន ខិតប័ណ្ណផ្សព្វផ្សាយ) | មាន-មិនមាន | ១ |
| **២១-I2** សូចនាករលំអិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់ប្រតិបត្តិករទេសចរណ៍ | វត្តមានឯកសារផ្សេងៗនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ដែលឯកសារទាំងនោះធ្វើឡើងសំដៅដល់ប្រតិបត្តិករទេសចរណ៍ទាំងឡាយ (កូនសៀវភៅការណែនាំ ) | មាន-មិនមាន | ១ |
| | ភាពញឹកញាប់នៃសកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់ប្រតិបត្តិករទេសចរណ៍ | យ៉ាងហោចណាស់១ដងក្នុងមួយឆ្នាំ | ១ |
| **២២-I3** សូចនាករលំអិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់ភ្ញៀវទេសចរ | វត្តមានមធ្យោបាយផ្តល់ព័ត៌មានអំពីបរិស្ថាន (បដា-ព័ត៌មាន និងខិតប័ណ្ណផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹង ។ល។) | មាន-មិនមាន | ១ |
| | សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថានធ្វើឡើងដោយប្រតិបត្តិករទេសចរណ៍នៅតាមគោលដៅទេសចរណ៍ | មាន-មិនមាន | ១ |
| - **ចំនួនសូនាករលំអិត ៖ ៣**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ៧** | | **សរុប** | **៧** |

## ៥. សូចនាករគោលនៃតំបន់បៃតង (មាន៣សូចនាករលំអិត)

| សូចនករគោលនៃតំបន់បៃតង | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| **២៣-V1** សូចនាករលំអិត | ភាគរយតំបន់បៃតងធៀបនឹងផ្ទៃក្រឡាទីក្រុងទាំងមូល | ធំជាង ៥% | ១ |

| | | | |
|---|---|---|---|
| នៃការបង្កើត និងបែងចែកតំបន់បៃតង | | | |
| **២៤**-V2 សូចនាករលំអិតនៃការថែទាំ និងរៀបចំតំបន់បៃតង | លើកកម្ពស់សោភណ្ឌភាពតំបន់បៃតងដែលមានស្រាប់ (ការដាក់ភ្លើងបំភ្លឺ កៅអីសាធារណៈ ផ្លូវដើរ) | មាន-មិនមាន | ១ |
| | ភាពញឹកញាប់ក្នុងការថែទាំតំបន់បៃតង | យ៉ាងហោចណាស់៣ដងក្នុងមួយសប្តាហ៍ | ១ |
| **២៥**-V3 សូចនាករលំអិតនៃការគ្រប់គ្រងតំបន់បៃតង | ការគិតគូរអំពីលក្ខខណ្ឌបរិស្ថានក្នុងការគ្រប់គ្រងតំបន់បៃតង (ការជ្រើសរើសទីតាំង វិធីស្រោចទឹក ការប្រើប្រាស់ជីកំប៉ុស។ល។) | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលំអិត ៖ ៣**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ៤** | | **សរុប** | **៤** |

## ៦. <u>សូចនាករគោលនៃសុវត្ថិភាពសុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង (មាន៣សូចនាករលំអិត)</u>

| **សូចនាករគោលនៃសុវត្ថិភាពសុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង** | **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| **២៦**-S1 សូចនាករលំអិតនៃសុវត្ថិភាពសុខាភិបាល | មានមណ្ឌលសុខភាពគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង | យ៉ាងហោចណាស់១ក្នុង១សង្កាត់ | ១ |
| | លទ្ធភាពនៃការត្រួតពិនិត្យអនាម័យតាមភោជនីយដ្ឋាន (ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល) | យ៉ាងហោចណាស់៣ដងក្នុងមួយខែ | ១ |
| | លទ្ធភាពនៃការត្រួតពិនិត្យអនាម័យតាមផ្សារលក់ចំណីអាហារ (ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល) | យ៉ាងហោចណាស់៣ដងក្នុងមួយខែ | ១ |
| | លទ្ធភាពនៃការត្រួតពិនិត្យអនាម័យរបស់អ្នកលក់ដូរចល័ត (ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល) | យ៉ាងហោចណាស់៣ដងក្នុងមួយខែ | ១ |
| | ភាគរយអាជីវកម្មដែលមានលិខិតបញ្ជាក់ពីក្រសួង ឬមន្ទីរសុខាភិបាល | យ៉ាងហោច ៧០% | ១ |

| | | | |
|---|---|---|---|
| ២៧-S2 សូចនាករលំអិតនៃសន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង | តើមន្ត្រីនគរបាលទេសចរណ៍មានចំនួនគ្រប់គ្រាន់ដែរឬទេបើធៀបនឹងចំនួនទេសចរ? | មាន-មិនមាន | ១ |
| | ភាគរយមន្ត្រីនគរបាលទេសចរណ៍ដែលបានទទួលការហ្វឹកហ្វាត់ជំនាញ (ភាសា និងការទទួលភ្ញៀវ) | យ៉ាងហោច ៨០% | ១ |
| | ចំនួនពាក្យបណ្តឹងដែលមានកម្មវត្ថុទាក់ទងនឹងសុវត្ថិភាព ភ្ញៀវទេសចរទទួលបានក្នុងមួយឆ្នាំៗ | តិចជាង១០ | ១ |
| | ភាគរយនៃអ្នកបើករថយន្តឈ្នួល ម៉ូតូឌុប រ៉ឺម៉កកង់បី ដែលមានឯកសណ្ឋាន | យ៉ាងហោច ៥០% | ១ |
| | តើមានការគិតគូរឲ្យមានជាចំណតសំរាប់ (រថយន្ត ម៉ូតូ កង់) នៅតាមវិថីសំខាន់ៗនៃទីក្រុងដែរឬទេ? | មាន-មិនមាន | ១ |
| | តើមានការគិតគូរលើចំណតសំរាប់ថ្ងៃគូ និងថ្ងៃសេស នៅតាមវិថីសំខាន់ៗនៃទីក្រុងដែរឬទេ? | មាន-មិនមាន | ១ |
| ២៨-S3 សូចនាករលំអិតនៃសកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើស | សកម្មភាពបង្ការនិងទប់ស្កាត់អំពើល្មើសទាក់ទងនឹងការជួញដូរផ្លូវភេទ (មានការបិតផ្សាយការត្រួតពិនិត្យលិខិតសម្គាល់ខ្លួនពេលចូលសណ្ឋាគារជាដើម) | មាន-មិនមាន | ១ |
| | សកម្មភាពបង្ការនិងទប់ស្កាត់អំពើល្មើសទាក់ទងនឹងការជួញដូរគ្រឿងញៀន (មានការបិតផ្សាយការត្រួតពិនិត្យលិខិតសម្គាល់ខ្លួនពេលចូលសណ្ឋាគារជាដើម) | មាន-មិនមាន | ១ |
| | សកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើសចោរកម្ម | មាន-មិនមាន | ១ |
| **- ចំនួនសូចនាករលំអិត ៖ ៣**<br>**- ចំនួនលក្ខណវិនិច្ឆ័យ ៖ ១៤** | | **សរុប** | **១៤** |

## ៧.សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ (មាន៤សូចនាករលំអិត)

| **សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍** | **លក្ខណៈវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ២៩-T1 សូចនាករលំអិតនៃហេដ្ឋារចនាសម្ព័ន្ធទីក្រុង | តើមានផ្លូវថ្នល់ (ផ្លូវកៅស៊ូ ផ្លូវបេតុង) គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | យ៉ាងហោចណាស់២៥%នៃផ្ទៃទីក្រុង | ១ |

| | | | |
|---|---|---|---|
| | តើមានមតេយ្យសាលា ឬសាលាបឋមសិក្សាគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | ៥០០ម៉ែត្រពីទីប្រជុំជន | ១ |
| | តើមានអនុវិទ្យាល័យគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | ១០០០ម៉ែត្រពីទីប្រជុំជន | ១ |
| | តើមានវិទ្យាល័យគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | ១៥០០ម៉ែត្រពីទីប្រជុំជន | ១ |
| | តើមានសួនកំសាន្តសំរាប់កុមារគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | យ៉ាងហោចណាស់ ១០% នៃតំបន់សាងសង់បាន | ១ |
| | តើមានទីតាំងសំរាប់លេងកីឡាគ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | យ៉ាងហោចណាស់ ១០% នៃតំបន់សាងសង់បាន | ១ |
| ៣០-T2 សូចនាករលំអិតនៃប្លង់មេសម្រាប់ការអភិវឌ្ឍទេសចរណ៍ | តើមានផែនការអភិវឌ្ឍទេសចរណ៍ដែរឬទេ? | មាន-មិនមាន | ១ |
| | តើមានផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រនៅក្នុងក្រុងដែរឬទេ? | មាន-មិនមាន | ១ |
| ៣១-T3 សូចនាករលំអិតនៃមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ | តើមានមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍នៅតាមតំបន់ទេសចរណ៍សំខាន់ៗគ្រប់គ្រាន់ដែរឬទេ? | គ្រប់គ្រាន់-មិនគ្រប់គ្រាន់ | ១ |
| ៣២-T4 សូចនាករលំអិតនៃទីតាំងលក់ទំនិញ | តើមានមជ្ឈមណ្ឌលពាណិជ្ជកម្ម (Shopping center) នៅក្នុងទីក្រុងដែរឬទេ? | យ៉ាងហោចណាស់ ១ | ១ |
| | តើមានផ្សាររាត្រីនៅក្នុងទីក្រុងដែរឬទេ? | យ៉ាងហោចណាស់ ១ | ១ |
| ៣៣-T5 សូចនាករលំអិតនៃកម្រិតភាពពេញចិត្តរបស់ភ្ញៀវទេសចរ | ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះការស្វាគមន៍រាក់ទាក់របស់ប្រជាជនមូលដ្ឋាន។ | យ៉ាងហោចណាស់៧០% | ១ |
| | ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះភាពស្អាតនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍។ | យ៉ាងហោចណាស់៧០% | ១ |
| | ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះការតុបតែងលំអនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍។ | យ៉ាងហោចណាស់៧០% | ១ |
| - **ចំនួនសូចនាករលំអិត ៖ ៥**<br>- **ចំនួនលក្ខណវិនិច្ឆ័យ ៖ ១៤** | | **សរុប** | **១៤** |

## II. យន្តការនៃការប្រឡងប្រណាំងទីក្រុងស្អាត

ការប្រើប្រាស់តារាងវាយតម្លៃ គឺផ្អែកលើការប្រៀបធៀបរវាងលក្ខណវិនិច្ឆ័យខុសៗគ្នានៃការប្រឡងប្រណាំង**ទីក្រុងស្អាត** ដែលបានរ៉ាយរ៉ាប់ខាងលើ ។

ការប្រៀបធៀបនេះនឹងអនុញ្ញាតឱ្យយើងកំណត់នូវការដាក់ពិន្ទុលើភាពស្អាត និងលើបរិស្ថាននៃទីក្រុងនីមួយៗ។

ការវាយតម្លៃ គឺជាគោលទុកសម្រាប់ធ្វើការវាស់វែងអំពីកម្រិតរបស់លក្ខណវិនិច្ឆ័យរបស់ទីក្រុងនីមួយៗ ថាតើលក្ខណវិនិច្ឆ័យទាំងនោះបានបំពេញលក្ខខណ្ឌនៃការប្រឡងប្រណាំងដែរឬទេ។

តារាងវាយតម្លៃនឹងអនុញ្ញាតឱ្យយើងធ្វើចំណាត់ថ្នាក់នៃទីក្រុងទេសចរណ៍ដោយមានការដាក់ពិន្ទុលើ ៧៧ ជាអនុគមន៍ទៅនឹងចំនួនពិន្ទុដែលទទួលបាន។ ស្លាកសញ្ញា (Logo) ៣ប្រភេទនឹងត្រូវផ្តល់ជូនជាអនុគមន៍ទៅនឹងចំនួនពិន្ទុដែលទទួលបាន។ ប្រភេទនៃស្លាកសញ្ញា (Logo) ឬរង្វាន់ នឹងត្រូវកំណត់ដោយគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។ ឧទាហរណ៍នៃការចែកជូនស្លាកសញ្ញា (Logo) ឬរង្វាន់ ៖

ស្លាកសញ្ញាផ្ការំដួល **៣ទង** ៖ នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបានពិន្ទុចន្លោះ **៥៨ និង ៧៧** លក្ខណវិនិច្ឆ័យ (យ៉ាងហោចណាស់ស្មើនឹង៧៥% នៃចំនួនពិន្ទុសរុប)

ស្លាកសញ្ញាផ្ការំដួល **២ទង** ៖ នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបាន ពិន្ទុចន្លោះ **៤៦ និង ៥៧** លក្ខណវិនិច្ឆ័យ (យ៉ាងហោចណាស់ស្មើនឹង៦០% នៃចំនួនពិន្ទុសរុប)

ស្លាកសញ្ញាផ្ការំដួល **១ទង** ៖ នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបាន ពិន្ទុចន្លោះ **៣១ និង ៤៥** លក្ខណវិនិច្ឆ័យ (យ៉ាងហោចណាស់ស្មើនឹង៤០% នៃចំនួនពិន្ទុសរុប)

**រៀបចំការប្រកួតថ្នាក់ជាតិគឺមានភាពសមរម្យជាងគេបំផុត ដោយសារប្រទេសកម្ពុជាមាន**ទីប្រជុំជន**ជាង៣០**[1] ដែលមានប្រជានជនលើសពី ១០០០០នាក់ (បច្ចុប្បន្នជាង២០ភាគរយនៃប្រជាជនរស់នៅក្នុងតំបន់ទីក្រុងនៃប្រទេសកម្ពុជា)។

[1] ប្រភពព័ត៌មានពីធានាគារពិភពលោក

## III. ដំណើរការនៃការប្រឡងប្រណាំង

- **ដំណាក់កាលទី១ ៖** ការបើកសិក្ខាសាលាដើម្បីបង្ហាញគម្រោងការប្រឡងប្រណាំងទីក្រុងស្អាតរៀបចំដោយគណៈកម្មាធិការជាតិទទួលបន្ទុកវាយតម្លៃទីក្រុងស្អាត ដោយមានវត្តមានចូលរួមរបស់អភិបាលខេត្តនានា។ សិក្ខាសាលានេះមានគោលបំណងដើម្បីបង្ហាញពី ៖

  -ទិដ្ឋភាពទូទៅនៃការប្រឡងប្រណាំងនេះ

  -កម្មវត្ថុនៃការប្រឡងប្រណាំង

  -និងបង្ហាញពីសូចនាករព្រមទាំងលក្ខណវិនិច្ឆ័យទាំងឡាយសម្រាប់ការវាយតម្លៃ។
- **ដំណាក់កាលទី២ ៖** ទីក្រុង[2]ទាំងអស់ត្រូវចូលរួមការប្រឡងប្រណាំងដោយកាតព្វកិច្ច។ ដើម្បីធ្វើការប្រកួតបានតម្លាភាព និងយុត្តិធម៌ យើងនឹងមានការចងក្រងជាក្រុមនៃប្រភេទទីក្រុងដែលមានទីក្រុងធំ ទីក្រុងមធ្យម និងទីក្រុងតូច។
- **ដំណាក់កាលទី៣ ៖** ការរៀបចំកម្មវិធី និងដំណើរទស្សនកិច្ចដល់ទីកន្លែងផ្ទាល់របស់គណៈកម្មាធិការជាតិ។ ដំណើរទស្សនកិច្ចនេះធ្វើឡើងក្នុងគោលបំណងធ្វើការវិនិច្ឆ័យទីក្រុងដោយយោងទៅលើតារាងវាយតម្លៃ។ ការត្រួតពិនិត្យនេះអាចធ្វើឡើងដោយការចុះទៅផ្ទាល់ដល់ទីរមណីយដ្ឋាន និងកន្លែងសាធារណៈផ្សេងៗរបស់ទីក្រុង និងធ្វើការសម្ភាសន៍ជាមួយអាជ្ញាធរក្រុងនិងអាជ្ញាធរពាក់ព័ន្ធក្នុងការបង្ហាញភស្តុតាងផ្សេងៗ។ ក្នុងករណីដែលគណៈកម្មាធិការជាតិទទួលបន្ទុកវាយតម្លៃទីក្រុងស្អាតមិនអាចចុះធ្វើទស្សនកិច្ចបាន ទីក្រុងដែលចូលរួមប្រកួតប្រជែងត្រូវកសាងឯកសារដោយភ្ជាប់ជាមួយរូបភាពមកគណៈកម្មាធិការជាតិ។
- **ដំណាក់កាលទី៤ ៖** ប្រកាសជ័យលាភីនៃការប្រកួតយោងតាមចំនួនលក្ខណវិនិច្ឆ័យដែលទីក្រុងបានបំពេញ។ ចំពោះទីក្រុងដែលទទួលបានពិន្ទុទាប (មិនជាប់ចំណាត់ថ្នាក់) អាចទទួលបានការប្រឹក្សានិងផ្តល់យោបល់បន្ថែមទៀតពីគណៈកម្មាធិការជាតិ ដើម្បីឱ្យពួកគាត់អាចបំពេញលក្ខណវិនិច្ឆ័យដែលខ្វះខាត និងអាចក្លាយជាជ័យលាភីសម្រាប់ការវិនិច្ឆ័យក្រោយៗទៀត។
- **ដំណាក់កាលទី៥ ៖** គណៈកម្មាធិការជាតិនឹងធ្វើការរៀបចំពិធីប្រគល់ស្លាកសញ្ញាជាផ្លូវការដល់ក្រុងដែលទទួលបានជ័យលាភី។ ទីក្រុងជ័យលាភីអាចទទួលបានចំណាត់ថ្នាក់ទៅតាមពិន្ទុដែលខ្លួនបំពេញបាន។

---

[2] ទីក្រុងសំដៅ **"ទីក្រុងទេសចរណ៍"** ៖ ជាបណ្តុំទីប្រជុំជនសំខាន់ៗដែលអាចជាក្រុង ស្រុក ឬខណ្ឌណាមួយនៃរាជធានី ភ្នំពេញ ដែលជាគោលដៅទាក់ទាញទេសចរណ៍។ **ទីក្រុង**ដែលចូលរួមក្នុងការប្រលងប្រណាំងទីក្រុងស្អាត ត្រូវតែជាទីក្រុងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា **"ទីក្រុងទេសចរណ៍"** ដូចមានចែងក្នុងនិយមន័យខាងលើនេះ រួមនឹងលក្ខខណ្ឌតម្រូវមួយចំនួនទៀត ដូចខាងក្រោម ៖

- មានប្រជាពលរដ្ឋរស់នៅក្រោមការគ្រប់គ្រងយ៉ាងតិច៣០ ០០០ នាក់
- ប្រជាពលរដ្ឋលើសពី ៥០% ប្រកបការងារក្នុងវិស័យពាណិជ្ជកម្ម
- ជាគោលដៅទាក់ទាញទេសចរណ៍(ដូចបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់ទេសចរណ៍) ៖ សំដៅដល់ទីកន្លែង ដែលមានភាពទាក់ទាញទេសចរណ៍ មានសម្បទាទេសចរណ៍ មានសេវាទេសចរណ៍បម្រើប្រកបដោយផាសុកភាព និងមានលទ្ធភាពអាចចូលទៅដល់បាន។

**<u>កំណត់សម្គាល់ ៖</u>**

- **ពេលវេលានៃការប្រកួត**
  - ការប្រកួតអាចនឹងត្រូវបានរៀបចំជារៀងរាល់៣ឆ្នាំម្តង
  - ទីក្រុងជ័យលាភីនឹងអាចទទួលបានស្លាកសញ្ញាដែលមានសុពលភាពសម្រាប់រយៈពេល៣ឆ្នាំ។
- **គណៈកម្មាធិការវាយតម្លៃ**
  - សមាជិកនៃគណៈកម្មាធិការវាយតម្លៃអាចមានតំណាងរបស់ក្រសួងទេសចរណ៍ ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ និងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។
  - គណៈកម្មាធិការត្រូវតែមានអធិបតេយ្យភាពក្នុងការផ្តល់ និងដកហូតស្លាកសញ្ញា និងត្រូវមាននីតិវិធីដំណើរការច្បាស់លាស់ ។
  - គណៈកម្មាធិការមានសិទ្ធិស្វយ័តធ្វើការកែប្រែ និងធ្វើបច្ចុប្បន្នភាពលើស្តង់ដារទីក្រុងស្អាតដើម្បីឱ្យស្របតាមការវិវត្តន៍ និងរីកចំរើនជាក់ស្តែងរបស់ទីក្រុងនាពេលអនាគត។